# នំប៉័ងសម្រាប់
# មនុស្សប្រាំពាន់នាក់



# សេចក្ដីផ្ដើម

ព្រះយេស៊ូបានធ្វើការអស្ចារ្យជាច្រើន។ នៅក្នុងម៉ាថាយ ១៤:១៣-២១ ទ្រង់ផ្ដល់អាហារដល់មនុស្សជាងប្រាំពាន់នាក់ ដោយប្រើនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ។ អត្ថបទគម្ពីរនេះ រំលឹកយើងថា ព្រះយេស៊ូយកចិត្តទុកដាក់ចំពោះសុខុមាលភាពខាងរូបកាយ និងខាងវិញ្ញាណរបស់យើង ហើយគ្មានអ្វីដែលមិនអាចទៅរួចសម្រាប់ទ្រង់ឡើយ។

ចំណុចសំខាន់។៖

•ព្រះជាម្ចាស់អាចធ្វើអ្វីដែលមិនអាចទៅរួច។

•ព្រះជាម្ចាស់យកចិត្តទុកដាក់នឹងសេចក្ដីត្រូវការរបស់យើង។

•ព្រះជាម្ចាស់អាចប្រើរបស់តូច។ ដើម្បីធ្វើរឿងអស្ចារ្យ។

## ការណែនាំសម្រាប់មេរៀន

សូមឲ្យកូនរបស់អ្នកអង្គុយជាមួយអ្នកនៅលើកន្ទេលសម្រាប់បរិភោគអាហារ។ រំលឹកកូនអ្នកថា ការអស្ចារ្យគឺជាអ្វីមួយដែលមិនអាចទៅរួច ប៉ុន្តែអាចទៅរួចសម្រាប់ព្រះជាម្ចាស់។ សុំឱ្យកូនរបស់អ្នករកនឹកការអស្ចារ្យណាមួយដែលពួកគេចងចាំពីព្រះគម្ពីរ។ លេងល្បែងជាមួយកូនអ្នកដោយសួរពួកគេ ដើម្បីរកឲ្យឃើញថា តើមានអ្វីដែលកើតឡើងជាការអស្ចារ្យឬអត់។ សួរសំណួរដូចជា "តើវាជាការអស្ចារ្យទេប្រសិនបើឆ្មាបរិភោគត្រី?" ឬ "តើវាជាការអស្ចារ្យទេ ប្រសិនបើយើងអាចនិយាយភាសាផ្សេង បានភ្លាម។?" ជាមួយព្រះជាម្ចាស់អ្វី។អាចទៅរួចទាំងអស់។

និយាយពីពេលដែលអ្នកឃ្លាន។ តើអ្នកធ្លាប់ឃ្លាននៅពេលធ្វើដំណើរដោយ កន្លែងលក់ម្ហូប ឬភោជនីយដ្ឋានត្រូវបានបិទនៅពេលអ្នកទៅដល់? សូមចែកចាយពីការដែលមនុស្សរាប់ពាន់នាក់បានទៅស្ដាប់ព្រះយេស៊ូបង្រៀន ហើយពួកគេទាំងអស់គ្នាឃ្លាន។ សួរថា "តើព្រះយេស៊ូបានធ្វើអ្វីខ្លះ?" តើទ្រង់បានប្រាប់ពួកគេឲ្យទិញអាហារឬទេ? តើទ្រង់បានប្រាប់ពួកគេថាពួកគេឆ្កួត ហើយដែលបានភ្លេចយកម្ហូបមកទេ? ព្រះយេស៊ូមានចិត្តអាណិតអាសូរ ហើយបានជួយមនុស្សដែលស្រេកឃ្លាន ដោយផ្ដល់អាហារឲ្យពួកគេ។ ចែកចាយពីការដែលពួកសិស្សគិតថា វាមិនអាចទៅរួច ប៉ុន្តែព្រះយេស៊ូមិនយល់ថា គ្មានអ្វីដែលមិនអាចទៅរួចទេសម្រាប់ព្រះជាម្ចាស់ឡើយ។

ដាក់នំ និងត្រីសាឌីនចំនួនប្រាំ ឬត្រីតូច។ (ឬក៏អាចកាត់រូបភាពនៅក្នុងសន្លឹកកិច្ចការ)។ សួរកូនរបស់អ្នកអំពីចំនួនមនុស្សដែលពួកគេគិតថា អាចញ៉ាំគ្រាន់។ ប្រើជញ្ជីងផ្ទះបាយ ដើម្បីថ្លឹងនំប៉័ងមួយដុំ។ កត់ទម្ងន់វា។ សុំឱ្យកូនអ្នកហែកនំប៉័ង ហើយរាប់ចំនួនដុំដែលពួកគេមាន។ វាហាក់ដូចជាមានច្រើន ដោយសារតែឡូវនេះវាជាបំណែក។។ ដាក់នំប៉័ងនៅលើជញ្ជីងវិញ ហើយមើលថាវាមានទម្ងន់ដូចគ្នាដដែល។

សូមពន្យល់ថា នៅពេលដែលព្រះយេស៊ូកាច់នំប៉័ងនោះ វាកាន់តែច្រើនឡើង។ ហើយមិនមែនគ្រាន់តែបរិមាណនោះទេ។ សូមពន្យល់ថាយើងមិនគួរគិតថាអ្វីដែលយើងអាចធ្វើ សម្រាប់ព្រះយេស៊ូគឺតូចតាចពេក ឬមិនសំខាន់នោះទេ។ ក្មេងប្រុសតូចម្នាក់មានអាហារថ្ងៃត្រង់ធម្មតា ប៉ុន្តែព្រះយេស៊ូបានប្រើវា ដើម្បីផ្គត់ផ្គង់អាហារដល់មនុស្សជាច្រើន។ ក្មេងនោះបានឲ្យអ្វីដែលគាត់មាន។ យើងគួរតែថ្វាយអ្វីដែលយើងមាន។ យើងក៏អាចធ្វើរឿងតូចតាចដែលព្រះអាចប្រើ ដើម្បីធ្វើកិច្ចការអស្ចារ្យ។

ធ្វើបញ្ជីនៃកិច្ចការតូចតាចដែលយើងអាចធ្វើបានដើម្បីបម្រើព្រះជាម្ចាស់ និងអ្នកដទៃ។ អធិស្ឋាន ហើយអរគុណព្រះជាម្ចាស់ដែលគ្មានអ្វីដែលមិនអាចទៅរួចសម្រាប់ទ្រង់ឡើយ។ សុំឱ្យទ្រង់ជួយអ្នកឲ្យតែងតែផ្ដល់នូវអ្វីដែលអ្នកមានចំពោះទ្រង់។

© 2020 truewaykids.com



នំប៉័ង និងត្រីមិនចេះអស់ឡើយ។ ពេលដែលពួកគេឱ្យកាន់តែច្រើនអាហារ កាន់តែ កើតចេញមក មនុស្សគ្រប់គ្នាបានញ៉ាំរហូត ដល់ពួកគេឆ្អែត។ ពេលពួកគេឈប់បរិភោគ ហើយ ពួកសិស្សបានរើសអាហារសល់។ វានៅសល់ដប់ពីរកន្ត្រក។

ទាំងអស់នេះ បានមកពីអាហារថ្ងៃត្រង់បន្តិចបន្តួចរបស់ ក្មេងប្រុសម្នាក់។






មនុស្សជាច្រើនចង់ស្ដាប់ព្រះយេស៊ូបង្រៀន។ មនុស្សមួយយ៉ាងកុះករបានដើរ តាមព្រះយេស៊ូទៅកន្លែងឆ្ងាយមួយ។ មានបុរសជាង ៥.០០០ នាក់បូកនឹងស្ត្រី និងកុមារ។

ពួកគេទាំងអស់គ្នាឃ្លាន។



សាវ័កទូលព្រះយេស៊ូឲ្យចាត់មនុស្សឲ្យទៅរកអាហារ។ ប៉ុន្តែព្រះយេស៊ូបានប្រាប់ពួកសាវ័កឲ្យផ្តល់អាហារដល់ពួកគេ។ ពួកសិស្សដឹងថារឿងនេះមិនអាចទៅរួចទេ។

វានឹងត្រូវចំណាយ ប្រាក់យ៉ាងច្រើន។

ប៉ុន្តែអនទ្រេបាននាំក្មេងប្រុសម្នាក់មករកព្រះយេស៊ូដែលកញ្ចប់អាហារថ្ងៃត្រង់។





ក្មេងប្រុសម្នាក់មាននំប៉ុងប្រាំដុំ និងត្រីពីរកន្ទុយ។ ព្រះយេស៊ូបានយកអាហារថ្ងៃត្រង់នេះ។ ទ្រង់បានអធិស្ឋាន ហើយអរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់អាហារ។

បន្ទាប់មកទ្រង់ចាប់ផ្តើមចែកនំប៉ុង និងត្រីដល់បណ្តាជន។

មានរឿងអស្ចារ្យកើតឡើង។

# សកម្មភាព និងល្បែងកម្សាន្ត

## ញ៉ាំអាហារពិកនិក

ក្មេងៗចូលចិត្តញ៉ាំអាហារពិកនិក។ វាជាឱកាសដ៏ល្អមួយក្នុងការអង្គុយ ជាមួយកូនអ្នក ហើយនិយាយលេង។ អ្នកអាចទៅឧទ្យានក្នុងតំបន់ ប៉ុន្តែពួកគេនឹងរីករាយនឹងការទទួលទានអាហារនៅសួនច្បារ ឬកន្លែងកំសាន្តក្នុងផ្ទះ។ វាក៏ជាឱកាសដើម្បីណែនាំអាហារដែលកូនរបស់អ្នកមិនបរិភោគជាប្រចាំ។ សុំឱ្យកូនរបស់អ្នកជួយអ្នករៀបចំសម្រាប់ការញ៉ាំអាហារ។ ធ្វើនំសាំងវិច រៀបចំកន្ត្រកអាហារ។ ល។ ចែកចាយថា តើអ្នកមានអាហារគ្រប់គ្រាន់សម្រាប់មនុស្សនៅកន្លែងពិកនិករបស់អ្នកឬអត់។





## ក្រុមនៃ ...

សម្រាប់ហ្គេមនេះអ្នកត្រូវការវត្ថុ ឬមនុស្សយ៉ាងតិច ១២ នាក់។ រំលឹកកូនៗរបស់អ្នកអំពីការដែលព្រះយេស៊ូបានមានបន្ទូលប្រាប់ពួកសិស្សឲ្យចែកមនុស្សជាក្រុម។ នៅពេលអ្នកនិយាយលេខ ឧទាហរណ៍: លេខ ២ កូនៗគួរចូលតាមក្រុម ឬវត្ថុជាក្រុមដែលមានពីរនាក់ក្នុងមួយក្រុម។ ល។

នេះជាហ្គេមល្អមួយ ដើម្បីរៀនជំនាញគណិតវិទ្យា។

## កុំភ្លេចអាហារថ្ងៃត្រង់របស់អ្នក

នេះគឺជាហ្គេមចងចាំដ៏ល្អមួយ ដើម្បីលេងជាមួយកូនៗ។ អ្នកនឹងត្រូវការកន្ត្រក ឬកាបូប និងរបស់របរប្រើប្រាស់មួយចំនួន។ មនុស្សទីមួយនិយាយថា “ខ្ញុំមាន (អាហារ) នៅក្នុងកញ្ចប់អាហាររបស់ខ្ញុំ” ដាក់អីវ៉ាន់ទៅក្នុងកន្ត្រក។ អ្នកលេងបន្ទាប់បន្ថែមរបស់ថ្មី ហើយត្រូវចងចាំអ្វីដែលមាននៅខាងក្នុង។ ឧទាហរណ៍: ខ្ញុំមាន (អាហារថ្មី) និងចេក និងផ្លែប៉ោមនៅក្នុងកន្ត្រកអាហាររបស់ខ្ញុំ។



© 2020 truewaykids.com

# ផាត់ពណ៌នំប៉័ងប្រាំដុំ



# ផាត់ពណ៌ត្រីពីរកន្ទុយ



© 2020 truewaykids.com

# រូបផ្គុំ



| | | | | | | |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |



| | | | | | | |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |

© 2020 truewaykids.com















© 2020 truewaykids.com

# ដប់ពីរ



12 12 12 12 12 12 12

12 12 12 12

12 12 12

12

តើសារីកប្រមូលនំប៉័ងនៅសល់បាន
ប៉ុន្មានកន្ត្រក ?

© 2020 truewaykids.com

# កន្ត្រកដាក់នំប៉័ង និងត្រី




## វត្ថុដែលត្រូវការ

ទំព័រពុម្ព
ខ្មៅដៃផាត់ពណ៌
កន្ត្រៃ
កាវ

## អ្វីដែលត្រូវធ្វើ




ផាត់ពណ៌ទំព័រពុម្ព




កាត់កន្ត្រក ដៃយួរ នំប៉័ង ត្រី និងពាក្យ។




បិតកាវកន្ត្រក។ បិតពាក្យនៅខាងក្រោយនំប៉័ង និងត្រី។

## ខចងចាំ

ជួយកូនអ្នកឱ្យរៀបចំនំប៉័ង និងត្រីដើម្បីបង្កើតខចងចាំពី ម៉ាថាយ ១៩:២៦.

© 2020 truewaykids.com




© 2020 truewaykids.com



# រីឯ

# ព្រះជាម្ចាស់

# វិញ

បិតពាក្យ នៅខាងក្រោយ

នំប៉័ង និងត្រី។

# អ្វីក៏ដោយ

# ព្រះអង្គធ្វើ

# កើតទាំងអស់

ម៉ាថាយ 19:26

© 2020 truewaykids.com



© 2020 truewaykids.com



© 2020 truewaykids.com



© 2020 truewaykids.com



© 2020 truewaykids.com

# ការថ្វាយបង្គំ

បទចម្រៀងណែនាំសម្រាប់ការថ្វាយបង្គំ។ មិនមែនផលិតដោយ Trueway Kids ទេ។ វីដេអូ YouTube គួរតែត្រូវបានប្រើសម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួន។



Nothing is Impossible

https://youtu.be/yF_5QZxm6rs

One Basket

https://youtu.be/SQ8qsaxRYWM

Miracle Song With 5 loaves and 2 fish

https://youtu.be/loU0elw2lsM



# ការអធិស្ឋាន

អរព្រះគុណព្រះដែលបានអញ្ជើញអ្នកឱ្យនៅអស់កល្បជានិច្ចជាមួយទ្រង់។ សុំឱ្យទ្រង់ជួយអ្នកឱ្យប្រាប់អ្នកដទៃទាំងអស់អំពីការអញ្ជើញដ៏អស្ចារ្យរបស់ទ្រង់។

# សប្តាហ៍បន្ទាប់

## សាខេ

## ថ្ងៃទី ១០ ខែកក្កដា ២០២០

ប្រសិនបើអ្នកមិនទាន់បានធ្វើវាទេ សូមចុះឈ្មោះ ដើម្បីទទួលបានមេរៀនបន្ទាប់តាមអ៊ីមែល។

truewaykids.com/subscribe/

© 2020 truewaykids.com